ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០៤៣ / ២១ សណ

## សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**កម្មវត្ថុ៖** គោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពន្យាពេលនៃការរៀបចំកិច្ចប្រជុំដើម្បីគោរពយករណ៍អំពីលទ្ធផលនៃការអនុវត្តគម្រោងរួមគ្នារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារពលករវិលត្រឡប់ពីប្រទេសថៃ និងសហគមន៍ទទួលពលករ ក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ដែលគ្រោងប្រារព្ធធ្វើនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១។

ទទួល លេខ: 603 ថ្ងៃ 09.03.21

**យោង៖**
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ លើលិខិតលេខ ០២៧ /២១ សណ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១
- ប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** នៅថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ដើម្បីរៀបចំកិច្ចប្រជុំគោរពយករណ៍អំពីលទ្ធផលនៃការអនុវត្តគម្រោងរួមគ្នារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារពលករវិលត្រលប់ពីប្រទេសថៃ និងសហគមន៍ទទួលពលករក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប។

គោរពតាមគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចប្រមុខរាជរដ្ឋាភិបាល** និង **សម្តេចក្រឡាហោម** ដើម្បីចូលរួមអនុវត្តវិធានការទប់ស្កាត់ ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ អគ្គលេខាធិការ គ.ជ.ប.ជ សូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ដើម្បី៖

- ពន្យាពេលនៃការរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលនៃការអនុវត្តគម្រោងរួមគ្នារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីការពារពលករវិលត្រលប់ពីប្រទេសថៃ និងសហគមន៍ទទួលពលករ ដែលគ្រោងនឹងប្រារព្ធធ្វើនាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ នៅទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ទៅប្រារព្ធធ្វើនាពេលក្រោយ តាមពេលវេលាសមស្របដោយសេចក្តីអនុគ្រោះបំផុត។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ សម្រេច និងស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃ ........ ខែ ........ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០២១

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**